# សេចក្តីប្រកាសព័ត៌មាន

នាថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១១ វេលាម៉ោង ២:៣០ រសៀល នៅសាលប្រជុំនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានប្រារព្ធកិច្ចប្រជុំទ្វេភាគីរវាងរដ្ឋបាលគយកម្ពុជា ដឹកនាំដោយ **ឯ.ឧ. បណ្ឌិត ប៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា និងរដ្ឋបាលគយវៀតណាម ដឹកនាំដោយ **បណ្ឌិត ង្វៀន ង៉ុកទុក** អគ្គនាយករដ្ឋបាលគយវៀតណាម ក្នុងគោលបំណងពិភាក្សាគ្នាលើកិច្ចសហប្រតិបត្តិការលើវិស័យគយជាពិសេសកិច្ចសម្រួលពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ។ កិច្ចប្រជុំនេះ គឺជាផ្នែកមួយនៃដំណើរទស្សនកិច្ចជាផ្លូវការ របស់គណៈប្រតិភូជាន់ខ្ពស់គយវៀតណាម រយៈពេល ៥ ថ្ងៃ(ពីថ្ងៃទី២៦ ដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១១) មកកាន់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាមកកាន់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដែរ ។

នៅក្នុងកិច្ចប្រជុំនេះ បន្ទាប់ពីបានលើកឡើងអំពីវឌ្ឍនភាព និងសមិទ្ធផលសម្រេចបាននាពេលថ្មីៗនេះរបស់អង្គភាពរៀងខ្លួនមក និងដោយយល់ថាការធ្វើពាណិជ្ជកម្មផ្លាស់ប្តូរទំនិញរវាងប្រទេសទាំងពីរកាន់តែកើនឡើងជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃនោះភាគីទាំងពីរបានចុះហត្ថលេខា និងព្រមព្រៀងគ្នាដូចតទៅ ÷

១. ភាគីទាំងពីរនឹងខិតខំបន្តពង្រឹងឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀតក្នុងការអនុវត្តអនុស្សរណៈយោគយល់គ្នារវាងរដ្ឋបាលគយនៃប្រទេសទាំងពីរដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៧ នាទីក្រុងហាណូយ ។

២. បន្តពង្រីកក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗថែមទៀត រួមទាំងការធ្វើសាមញ្ញកម្មនីតិវិធីគយ និងការពង្រឹងប្រសិទ្ធភាពនៃការជួយគ្នាទៅវិញទៅមកជាពិសេសកិច្ចសហការលើផ្នែកបង្ការ និងបង្ក្រាបការគេចពន្ធ ការនាំចូលដោយខុសច្បាប់នូវថ្នាំញៀន គ្រឿងសញ្ញាវុធ និងបទល្មើសឆ្លងកាត់ព្រំដែនផ្សេងទៀត ។ ភាគីទាំងពីរក៏បានយល់ព្រមលើការកែលម្អយន្តការ នៃការផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវព័ត៌មានពាក់ព័ន្ធនឹងបទល្មើសទាំងនេះ ដើម្បីអាចចាត់វិធានការ និងរាយការណ៍អំពីលទ្ធផលបានទាន់ពេលវេលា ។

៣. បន្តជម្រុញការផ្លាស់ប្តូរព័ត៌មានគ្នា លើផ្នែកស្ថិតិពាណិជ្ជកម្ម បច្ចេកទេស និងនីតិវិធីគយ ព្រមទាំងការវិវត្តនានានៃបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធរបស់អង្គភាពរៀងៗខ្លួន ។

៤. ផ្តល់ការគាំទ្រគ្នាទៅវិញទៅមក នៅក្នុងវេទិកាគយពហុភាគី ដូចជានៅក្នុង ASEAN, GMS, WCO, APEC, ASEM, និង WTO ជាដើម ។

៥. បន្តជំរុញការអនុវត្តកិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យតែមួយលើកនៅមាត់ច្រកព្រំដែនបាវិត(កម្ពុជា)-មុកបៃ (វៀតណាម) រវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានគយវៀតណាម ។

៦. ជំរុញបញ្ចប់ការចរចារ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងត្រីភាគី ស្តីពីការដឹកជញ្ជូនឆ្លងកាត់ព្រំដែន រវាងកម្ពុជា-ឡាវ-វៀតណាម ក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍ ព្រមទាំងបង្កើតនីតិវិធីពិសេសសម្រាប់តំបន់នេះផងដែរ។

កិច្ចប្រជុំទ្វេភាគីនេះ បានបញ្ចប់នាម៉ោង ៥:០០ រសៀល ថ្ងៃដដែល បន្ទាប់ពីពិធីចុះហត្ថលេខាលើខ្លឹមសារដែលបានព្រមព្រៀងគ្នាក្នុងកិច្ចប្រជុំ ក្រោមបរិយាកាសមិត្តភាព រីករាយ និងស្និទ្ធស្នាលក្រៃលែង ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១១

# Press Release

In Phnom Penh, Cambodia on April 27, 2011 2:30PM at the Meeting Hall of GDCE, a Bilateral Meeting between the General Department of Customs and Excise of Cambodia, headed by **H.E. Dr. Pen Siman**, Delegate of the Royal Government in charge of the General Department of Customs and Excise of Cambodia, and the General Department of Vietnam Customs, headed by **Dr. Nguyen Ngoc Tuc**, Director General of the General Department of Vietnam Customs, has been held to enhance cooperation in Customs matters especially trade facilitation. This meeting is a part of the official 5-day visit of the delegations of Vietnam Customs (26 to 29$^{th}$ April, 2011) to Kingdom of Cambodia as well as the General Department of Customs and Excise of Cambodia.

After each side raised about the recent developments and achievments and considering the on-going increase in trade volume between Cambodia and Vietnam, the both sides agreed as the following:

1. Pledged to continue to enhance the effective implementation of the MOU between the two customs authorities signed on January 15th 2007 in Hanoi and further enhance their cooperative relationship for the benefit of both sides;
2. Will broaden the area of mutual administrative assistance, simplify the procedure and improve the mutual assistance more effectively. Specially, the two Sides will continue to cooperate effectively in preventing and dealing with smuggling, commercial frauds, narcotics, drugs, weapons, and other illegal goods trafficking across the border. They shall continue to improve the mechanism to provide each other with useful information on these illegal activities in order to take timely appropriate action against them.
3. To further exchange information on trade statistics, customs techniques, as well as significant changes in customs legislations and customs procedures of the two Sides;
4. To cooperate and support each other in the multilateral customs forum such as ASEAN, GMS, WCO, APEC, ASEM, and WTO;
5. Pledged to further promote the implementation of the Arrangement for Initial Implementation of Single Stop Inspection at Bavet, The Kingdom of Cambodia and Moc Bai, The Socialist Republic of Vietnam, by and between the General Department of Customs Excise of Cambodia and the General Department of Vietnam Customs;
6. Pledged to cooperate with each other to further simplify customs procedures such as pushing the process of concluding Tri-lateral Agreement on Cross-Border Transportation among Cambodia-Laos-Vietnam in the Developing Triangle Area;

The meeting finished ot 05:00 PM on the same day with workable happy and friendly's atmosphere.

Phnom Penh, 27$^{th}$ April, 2011